**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## រូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០២០១/០៣០ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីសញ្ញារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតរូបសញ្ញារបស់អង្គភាពប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ប្រើប្រាស់ជាផ្លូវការ ។

**មាត្រា២.-**

រូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយមានរូបភាព និងខ្នាតដូចតទៅ ៖

- ខ្សែរង្វង់រាងពងក្រពើមានផ្ទៃអមសងខាងពណ៌ខៀវ និងផ្ទៃខាងក្នុងពណ៌ក្រហមមានចារឹកអក្សរខ្មែរពណ៌ស " ព្រះរាជាណាចក្រកម្ពុជា " នៅផ្នែកខាងលើ និងអក្សរឡាតាំងថា " KINGDOM OF CAMBODIA " នៅផ្នែកខាងក្រោម តំណាងឱ្យប្រជាជាតិខ្មែរ

- នៅខាងក្នុងរង្វង់រាងពងក្រពើនេះ មានផ្ទៃពណ៌ស រំលេចដោយរូបសញ្ញារាជរដ្ឋាភិបាលពណ៌មាសតំណាងឱ្យស្ថាប័ននីតិប្រតិបត្តិ
- នៅផ្នែកខាងក្រោមរូបសញ្ញារាជរដ្ឋាភិបាល មានចារឹកអក្សរខ្មែរពណ៌ខៀវថា " អង្គភាពប្រឆាំងអំពើពុករលួយ " និងអក្សរកាត់អ.ប.អ.ព តំណាងឱ្យស្ថាប័នដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងអំពើពុករលួយ
- ផ្ទៃពណ៌ស និងអក្សរពណ៌ស តំណាងឱ្យសុចរិតភាពនៃសង្គមជាតិ
- ខ្សែបូរពណ៌មាសទ្រពីក្រោមរូបសញ្ញាខាងលើ មានចារឹកអក្សរឡាតាំងពណ៌ស ថា " ANTI-CORRUPTION UNIT " និងអក្សរកាត់ថា " ACU " តំណាងឱ្យការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការពីសហគមន៍តំបន់ និងអន្តរជាតិក្នុងការប្រឆាំងអំពើពុករលួយ
- មានទទឹង ៣ ភាគ ៤ នៃបណ្តោយ ។

រូបសញ្ញាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៣.-**

រូបសញ្ញារបស់អង្គភាពប្រឆាំងអំពើពុករលួយសម្រាប់ប្រើប្រាស់ ដូចខាងក្រោម ÷

- ដាក់នៅកន្លែងធ្វើការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់អង្គភាពប្រឆាំងអំពើពុកលួយ
- បំពាក់លើអាវរបស់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ នៃអង្គភាពប្រឆាំងអំពើពុករលួយ
- ប្រើប្រាស់សម្រាប់អង្គភាពប្រឆាំងអំពើពុករលួយ និងក្នុងករណីផ្សេងៗទៀត។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សូមចុះហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សុខ អាន**

**កន្លែងទទួល**

ងព្រះបរមរាជវាំង
បខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
បខាធិការដ្ឋានព្រឹទ្ធសភា
បខាធិការដ្ឋានរដ្ឋសភា
ល័យសម្តេចនាយករដ្ឋមន្ត្រី
ល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
ត្រា ៤
ឋ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០៨

ស្តីពីរូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយ




រូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយ

LOGO OF THE ANTI-CORRUPTION UNIT